# GEAR UP PHILADELPHIA

## សហគមន៍នៃការសហការត្រៀមខ្លួនសម្រាប់ មហាវិទ្យាល័យ និង អាជីព (CRCC)

### តើ GEAR UP គឺជាអ្វី?

កម្មវិធី GEAR UP (ការទទួលបាន ការយល់ដឹង និង ការត្រៀមខ្លួនជាស្រេចសម្រាប់កម្មវិធីថ្នាក់បរិញ្ញា( ដែលត្រូវបានគេរៀបចំឡើង ដើម្បីបង្កើនចំនួនសិស្សនៃក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបដែលបានត្រៀមទៅរៀន និង ទទួលបានជោគជ័យ ក្នុងការអប់រំក្រោយមធ្យមសិក្សា

### គំរូថ្មី

គំរូសហគមន៍នៃការសហការត្រៀមខ្លួនសម្រាប់ មហាវិទ្យាល័យ និង អាជីព (CRCC) គឺជាគំនិតផ្តួចផ្តើមកសាងសមត្ថភាព រៀបចំឡើងសម្រាប់ សិស្សានុសិស្ស និង សាលា ដែលមានរយៈពេលលើសពីការកំណត់របស់ប្រាក់ជំនួយសហព័ន្ធ ដែលផ្តោតទៅលើការសម្របសម្រួល ការចូលរួមចំណែកជាដៃគូ និង ការកសាងរចនាសម្ព័ន្ធនៃការសហការគ្នា នៅតាមសាលា។




### សាលាដែលយើងផ្តល់ការបម្រើ

ក្នុងរយៈពេល ៧ ឆ្នាំ ចាប់ពីឆ្នាំ ២០១៤-២០២១ យើងនឹងផ្តល់ការបម្រើដល់សាលាដែលគេបានកំណត់ តាមរយៈគម្រោងថវិកាចំនួន ២៩,៨ លានដុល្លារ។ នេះរួមបញ្ចូលទាំងចំនួនសិស្សសរុប ៦.០០១ នាក់ ដែលយើងបានបម្រើក្នុងគំរូរយៈពេល ២ ឆ្នាំ ដែលអនុញ្ញាតិឱ្យយើងតាមដាន និង សង្កេត នៅពេលដែលពួកគេទៅរៀននៅមហាវិទ្យាល័យ។ ក្នុងកំឡុងឆ្នាំ ២០១៧-២០២១ យើងផ្តោតសេវាកម្មទាំងស្រុងទៅលើវិទ្យាល័យចំនួន ២១ ដូចបានរាយឈ្មោះខាងលើ។

### គោលបំណងរបស់កម្មវិធី

- បង្កើនការសិក្សា និង ការរៀបចំសម្រាប់ការអប់រំក្រោយមធ្យមសិក្សាសម្រាប់សិស្ស GEAR UP។
- បង្កើនអត្រានៃការបញ្ចប់ការសិក្សានៅវិទ្យាល័យ និងការចុះឈ្មោះចូលរៀនក្រោយមធ្យមសិក្សាសម្រាប់សិស្ស GEAR UP។
- បង្កើនចំណេះដឹងរបស់សិស្សនិងក្រុមគ្រួសាររបស់ពួកគេ អំពីជម្រើសនៃការអប់រំក្រោយមធ្យមសិក្សា ត្រៀមខ្លួន និង រកជំនួយថិកាសម្រាប់បង់ថ្លៃសាលា។